# សេចក្តីថ្លែងការណ៍រួម
# “ច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មានជាគន្លឹះសំខាន់ក្នុងការជំរុញការវិនិយោគ និងកំណើនសេដ្ឋកិច្ចនៅកម្ពុជា”

សង្គមស៊ីវិលស្នើអោយរាជរដ្ឋាភិបាល និងស្ថាប័នសភាជាតិអនុម័តច្បាប់សិទ្ធិទទួលព័ត៌មានឱ្យបានឆាប់ស្របតាមបទដ្ឋានអន្តរជាតិ និងធានាបាននូវសិទ្ធិសេរីភាពក្នុងការទទួលបានព័ត៌មានដើម្បីលើកកម្ពស់សេវាសាធារណៈ និងដំណោះស្រាយបញ្ហាប្រឈមនានាលើគ្រប់វិស័យ ។

បន្ទាប់ពីជាងមួយទសវត្សរ៍ចាប់តាំងពីការតាក់តែងសេចក្តីព្រាងច្បាប់ដ៏សំខាន់នេះជាលើកដំបូង ប្រជាជនកម្ពុជា នៅមានកង្វល់អំពីការទទួលបានព័ត៌មានសាធារណៈនៅឡើយ ព្រោះទាំងរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ នៅមានភាពស្ទាក់ស្ទើរក្នុងការបើកចំហ ឬ ផ្សព្វផ្សាយព័ត៌មានមួយចំនួនដោយសារខ្វះខាតធនធាន និងសមត្ថភាពមានកម្រិត បើទោះបីជាគោលការណ៍អន្តរជាតិ និងជាតិអំពាវនាវឱ្យរដ្ឋបាលសាធារណៈយកចិត្តទុកដាក់ក្នុងការបំពេញតួនាទី និងការទទួលខុសត្រូវរបស់ខ្លួនក្នុងការបើកចំហព័ត៌មានក៏ដោយ។

នៅក្នុងប្រទេសជាតិដែលទំនើប និងជាពិសេសប្រទេសដែលប្រាថ្នាចង់ក្លាយខ្លួនជាប្រទេសអភិវឌ្ឍន៍ដែលមានចំណូលមធ្យម ព័ត៌មានសាធារណៈគឺជាគន្លឹះមួយនៃភាពជោគជ័យ។

សាធារណៈត្រូវការព័ត៌មានដើម្បីតាមដានការងាររបស់តំណាងរបស់ខ្លួននៅគ្រប់កម្រិត ហើយវិស័យឯកជនត្រូវការព័ត៌មានដើម្បីបង្កើតយុទ្ធសាស្រ្តអាជីវកម្ម សេចក្តីព្រាងផែនការរយៈពេលវែង និងធ្វើការសម្រេចចិត្តទាក់ទងនឹងការវិនិយោគ។ ប្រសិនបើមិនមានតម្លាភាព និងការទទួលបានឯកសារ ថវិកាកិច្ចសន្យាសាធារណៈ និងទិន្នន័យហិរញ្ញវត្ថុដែលរឹងមាំទេ នោះមិនមានក្រុមហ៊ុនប្រាកដណាមួយ ខ្នាតតូច មធ្យម ឬធំ បរទេស ឬក្នុងស្រុក នឹងប្តេជ្ញាចិត្តលើធនធានដែលត្រូវការសម្រាប់ការរីកចម្រើននៃប្រទេសរបស់យើងឡើយ។

ការរីករាលដាលនៃជំងឺកូវីដ-១៩បានបង្ហាញឱ្យឃើញពីសារៈសំខាន់នៃតួនាទីរបស់រាជរដ្ឋាភិបាលក្នុងការអនុវត្តសិទ្ធិទទួលព័ត៌មានយ៉ាងសកម្មក្នុងការផ្សព្វផ្សាយព័ត៌មានក្នុងវិស័យសុខាភិបាល។ ពេលថ្មីៗនេះ រាជរដ្ឋាភិបាលបានបើកចំហទិន្នន័យទាក់ទងគម្រោងអភិវឌ្ឍថ្នាក់ជាតិមួយចំនួន នេះជាការចូលរួមចំណែក

ដ៏សំខាន់ក្នុងការលើកកម្ពស់សិទ្ធិទទួលព័ត៌មាននៅកម្ពុជា។ ទោះជាយ៉ាងណាក៏ដោយ ដំណើរការនៃការផ្ដល់ និងទទួលព័ត៌មានសាធារណៈផ្សេងៗទៀតនៅមានកម្រិតនៅឡើយ ដែលប៉ះពាល់ជាយថាហេតុដល់សិទ្ធិ និងផលប្រយោជន៍នានារបស់ប្រជាពលរដ្ឋ ជាពិសេសលើបញ្ហាសំខាន់ៗដូចជាគម្រោងអភិវឌ្ឍន៍ធំៗកិច្ចសន្យាលទ្ធកម្មសាធារណៈជាតិ ក៏ដូចជាសម្បទានដីសេដ្ឋកិច្ច បញ្ហាដីធ្លី និងការបណ្ដេញចេញដោយបង្ខំ និងជម្លោះផ្សេងទៀតដែលពាក់ព័ន្ធដោយផ្ទាល់លើសិទ្ធិ និងសុខុមាលភាពរបស់ប្រជាពលរដ្ឋជាច្រើន។

ក្រុមការងារសិទ្ធិទទួលព័ត៌មាននៃអង្គការសង្គមស៊ីវិល និងយុវជនទទួលស្គាល់ការខិតខំប្រឹងប្រែងមួយចំនួនរបស់រាជរដ្ឋាភិបាលក្នុង ការលើកកម្ពស់សិទ្ធិទទួលព័ត៌មាន ជាពិសេសនៅថ្នាក់ក្រោមជាតិតាមរយៈកម្មវិធីមួយចំនួនដូចជា អភិបាលកិច្ចល្អមូលដ្ឋាន ក្របខ័ណ្ឌគណនេយ្យភាពសង្គម ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ និងការិយាល័យច្រកចេញចូលតែមួយជាដើម។ ការប្ដេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលក្នុងការចាប់ផ្ដើមដំណើរការធ្វើសេចក្ដីព្រាងច្បាប់ ស្ដីពី សិទ្ធិទទួលព័ត៌មានទទួលបានការកោតសរសើរពីក្រុមការងារអង្គការសង្គមស៊ីវិល។ ក្នុងជំនួបជាមួយអ្នកសារព័ត៌មានក្នុងស្រុកលើកទី៥ កាលពីថ្ងៃទី១១ ខែមករា ឆ្នាំ២០២៣ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន អតីតនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានប្ដេជ្ញាចិត្តអនុម័តច្បាប់ស្ដីពីការទទួលព័ត៌មានក្នុងឆ្នាំ២០២៤ ឬយ៉ាងយូរឆ្នាំ២០២៥ ក្នុងអាណត្តិសភាលើកទី៧។

ក្នុងឱកាសអបអរសាទរទិវាអន្តរជាតិ សម្រាប់ទិវាសិទ្ធិទទួលព័ត៌មានជាសកលឆ្នាំ២០២៤ ក្រោមប្រធានបទ "ច្បាប់ស្ដីពីសិទ្ធិទទួលព័ត៌មានជាគន្លឹះសំខាន់ក្នុងការជំរុញការវិនិយោគ និងកំណើនសេដ្ឋកិច្ចនៅកម្ពុជា"។ ក្រុមការងារសិទ្ធិទទួលព័ត៌មាននៃអង្គការសង្គមស៊ីវិល សូមស្នើជូន **សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** និងរាជរដ្ឋាភិបាល៖

- ពន្លឿនការអនុម័តច្បាប់ស្ដីពីសិទ្ធិទទួលបានព័ត៌មាន ដែលស្របតាមបទដ្ឋានអន្តរជាតិ ក្នុងឆ្នាំ២០២៤ យ៉ាងយូរត្រឹមឆ្នាំ២០២៥។
- សូមបញ្ជាក់ឱ្យបានច្បាស់អំពីព័ត៌មានណាខ្លះជាប្រភេទព័ត៌មានសម្ងាត់ ក្នុងច្បាប់ស្ដីពីសិទ្ធិទទួលព័ត៌មាន។
- ណែនាំក្រសួង មន្ទីរ និងអង្គភាពនានារបស់រដ្ឋ បើកចំហព័ត៌មានសាធារណៈឱ្យបានទូលំទូលាយជាពិសេស តម្លៃសេវាកម្ម នីតិវិធីក្នុងការទទួលបានសេវាសាធារណៈ និងពេលវេលាកំណត់ដោយច្បាប់នៅ កម្រិតថ្នាក់ជាតិ ព័ត៌មានសេដ្ឋកិច្ច និងការវិនិយោគ កិច្ចសន្យាដីសម្បទានសេដ្ឋកិច្ច គម្រោងអភិវឌ្ឍន៍ធំៗ គម្រោងលទ្ធកម្មសាធារណៈថ្នាក់ជាតិ បញ្ហាដីធ្លី ការបណ្ដេញចេញដោយបង្ខំ និងវិវាទដីទៃទៀត។
- ពង្រឹង និងបង្កើតនូវយន្តការទាំងឡាយជាពិសេសយកចិត្តទុកដាក់លើការផ្សព្វផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយគ្រប់ប្រភេទ ដើម្បីធានាថាប្រជាពលរដ្ឋ ក្រុមយុវជន ជនមានពិការភាព និងជនជាតិដើមភាគតិច ទទួលបាននូវព័ត៌មានពេញលេញ។

- ផ្តល់កិច្ចការពារចំពោះប្រជាពលរដ្ឋគ្រប់រូបដែលបានបង្ហាញ និងចែកចាយនូវព័ត៌មានពិតប្រាកដ ឬ ព័ត៌មានទាំងឡាយណាដែលបម្រើដល់ប្រយោជន៍សាធារណៈ។
- ផ្សព្វផ្សាយឱ្យបានទូលំទូលាយអំពី សិទ្ធិទទួលបានព័ត៌មាន និងលើកទឹកចិត្តប្រជាពលរដ្ឋ ជាពិសេស យុវជនឱ្យចូលរួមក្នុងការស្វែងរកព័ត៌មានសាធារណៈទាំងឡាយដែលពាក់ព័ន្ធនឹងជីវភាពរស់នៅប្រចាំថ្ងៃ។
- បង្កើតឱ្យមានបរិយាកាសកាន់តែប្រសើរឡើង សម្រាប់ការចូលរួមរបស់ប្រជាពលរដ្ឋ ជាពិសេស យុវជនក្នុងដំណើរការអភិវឌ្ឍន៍ប្រទេសកម្ពុជា។

ថ្ងៃសុក្រ ១០កើត ខែភទ្របទ ឆ្នាំរោង ឆស័ក ព.ស ២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២៤

ព័ត៌មានបន្ថែមសូមទំនាក់ទំនង៖
លោក **ឡាំ សុជាតិ** នាយកប្រតិបត្តិ វិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ (API)
តំណាងអង្គការសង្គមស៊ីវិលចំនួន ១៨ ធ្វើការលើកកម្ពស់សិទ្ធិទទួលព័ត៌មាន (A2IWG)
ទូរសព្ទ៖ ០១២ ៧១៨ ៦១១